# សេចក្ដីជូនដំណឹងអំពីការលះបង់សិទ្ធិ

## សេចក្ដីជូនដំណឹងរបស់ មាស មុត អំពីចេតនាអនុវត្តសិទ្ធិនៅស្ងៀម និង លះបង់សិទ្ធិចូលរួមសវនាការ លើបណ្ដឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ

ខ្ញុំបាទឈ្មោះ **មាស មុត** តាមរយៈនេះសូមជូនដំណឹងដល់អង្គបុរេជំនុំជម្រះថា ខ្ញុំបាទមិនមានបំណងនឹងចូលរួមសវនាការលើបណ្ដឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយដែលធ្វើឡើងនៅថ្ងៃទី ២៧ ដល់ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៩ ឡើយ[1]។ សហមេធាវីរបស់ខ្ញុំបាទបានផ្ដល់ដំណឹងដល់ខ្ញុំបាទ អំពីកាលបរិច្ឆេទសវនាការ ព្រមទាំងសិទ្ធិរបស់ខ្ញុំបាទក្នុងការពារក្ដីដោយខ្លួនឯងផ្ទាល់ សិទ្ធិបញ្ចេញមតិយោបល់នៅចុងបញ្ចប់សវនាការ[2] និង សិទ្ធិនៅស្ងៀម។ ខ្ញុំបាទគ្មានចេតនានឹងបញ្ចេញមតិយោបល់ឡើយ ហើយមានចេតនាពេញលេញអនុវត្តសិទ្ធិនៅស្ងៀម។ ខ្ញុំបាទលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយដឹងជាមុន ដោយមានសតិបញ្ញា ដោយស្ម័គ្រចិត្ត និង ដោយជាក់ច្បាស់ និង បង្គាប់សហមេធាវីរបស់ខ្ញុំបាទគឺ លោក អាង ឧត្ដម និង លោក ម៉ៃខល ខាណាវ៉ាស (Mr. Michael G. KARNAVAS) ឱ្យតំណាងផលប្រយោជន៍របស់ខ្ញុំបាទ។

នៅពេលប្រឹក្សាជាមួយសហមេធាវីរបស់ខ្ញុំបាទ ខ្ញុំបាទបានពិនិត្យ និង ពិភាក្សាលើគ្រប់ឯកសារទាំងអស់ដែលដាក់ដោយសហព្រះរាជអាជ្ញា និង មេធាវីការពារក្ដី ហើយនិងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ និង អន្តរជាតិ ព្រមទាំងសារណាផ្សេងៗទៀតដែលដាក់ដោយក្រុមមេធាវីការពារក្ដីរបស់ខ្ញុំបាទផងដែរ។ សារណាបណ្ដឹងឧទ្ធរណ៍របស់ខ្ញុំបាទត្រូវបានដាក់ តាមរយៈការបង្គាប់ណែនាំរបស់ខ្ញុំបាទទៅកាន់សហមេធាវីរបស់ខ្ញុំបាទ។ ខ្ញុំបាទពេញចិត្តនឹងការតវ៉ា ដែលសហមេធាវីរបស់ខ្ញុំបាទបានធ្វើនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្ញុំបាទ ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

---

[1] សារអេឡិចត្រូនិចផ្ញើពីមន្ត្រីសំណុំរឿងរបស់អង្គបុរេជំនុំជម្រះ ចំណងជើងថា "សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៣៥) សេចក្ដីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះទៅភាគី និង ការិយាល័យរដ្ឋបាល" ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០១៩ (ឯកសារភ្ជាប់ ១)។

[2] *សូមមើល រឿងក្ដី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស. (អ.ប.ជ.៦០) ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១៩ ឯកសារ D359/5 ទំព័រ ២។

ខ្ញុំបាទក៏បានដឹងតាមរយៈសហមេធាវីរបស់ខ្ញុំបាទផងដែរថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលបានបញ្ជូនសំណុំរឿងរបស់ខ្ញុំបាទទៅជំនុំជម្រះនៅក្នុងសវនាការ បានសម្រេចថា មិនមានការចាំបាច់ក្នុងការឃុំខ្លួនខ្ញុំបាទនោះឡើយ ដោយហេតុថា ខ្ញុំបាទត្រូវបានស្គាល់ជាយូរមកហើយថាស្ថិតនៅក្រោមការស៊ើបអង្កេត បានចូលរួមសហការជាមួយសហចៅក្រមស៊ើបអង្កេត ហើយខ្ញុំបាទមិនមានភ័យយន្តរាយក្នុងការរត់ចេញពីប្រទេស ឬ ផ្តល់ការរំខានដល់ជនរងគ្រោះ សាក្សី ដំណើរការតុលាការ ឬ សណ្តាប់ធ្នាប់សាធារណៈឡើយ។

ខ្ញុំបាទនៅតែជឿជាក់ថា លោក អាង ឧត្តម និង លោក ម៉ៃខល ខាណាវ៉ាស (Mr. Michael G. KARNAVAS) នឹងការពារក្តីរបស់ខ្ញុំបាទ យ៉ាងមុតមាំ និង មិនធ្វើអ្វីផ្ទុយពីផលប្រយោជន៍ដ៏ល្អបំផុតរបស់ខ្ញុំបាទ នៅឯសវនាការលើបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយឡើយ។

សុំទទួលយកសេចក្តីគោរពអំពីខ្ញុំបាទ។

| | | |
|---|---|---|
| | | 14-10-2019 |
| មាស មុត | ហត្ថលេខា | កាលបរិច្ឆេទ |

# NOTICE AND WAIVER

## MEAS MUTH'S NOTICE OF INTENT TO EXERCISE RIGHT TO REMAIN SILENT AND WAIVER OF RIGHT TO ATTEND HEARINGS ON THE APPEALS AGAINST THE CLOSING ORDERS

I, **MEAS Muth**, hereby provide notice to the Pre-Trial Chamber that I do not wish to attend the hearings on the appeals against the Closing Orders on 27 to 29 November 2019.[1] My Co-Lawyers have informed me of the hearing dates and of my rights to defend myself in person, to make a personal statement at the end of the hearings,[2] and to remain silent. I have no intention of making a personal statement and fully intend to exercise my right to remain silent. I knowingly, intelligently, voluntarily, and unequivocally waive my right to attend the hearings and instruct my Co-Lawyers, Mr. ANG Udom and Mr. Michael G. KARNAVAS, to represent my interests.

In consultation with my Co-Lawyers, I have reviewed and discussed all documents filed by the Co-Prosecutors and Defence and the International and National Co-Investigating Judges' Closing Orders, as well as other submissions filed by my Defence team. My appellate submissions were filed based on my instructions to my Co-Lawyers. I am satisfied with the challenges my Co-Lawyers made in my appeal against the International Co-Investigating Judge's Indictment.

I have also been informed by my Co-Lawyers that the International Co-Investigating Judge who indicted me did not consider it necessary to detain me because I have known for years that I am under investigation, have engaged with the Co-Investigating Judges, and am not a flight risk nor risk to any victims, witnesses, the judicial process, or public order.

I remain confident that Mr. ANG Udom and Mr. Michael G. KARNAVAS will defend me vigorously and will not take any action contrary to my best interests at the hearings on the appeals against the Closing Orders.

Respectfully submitted,

[signature] 14-10-2019

MEAS Muth — Signed in — on

---

[1] Email from the Pre-Trial Chamber's Case File Officer titled "Case File Nº 003/07-09-2009-ECCC/OCIJ (PTC35), Pre-Trial Chamber's Notification to the Parties and the Office of Administration," 25 September 2019 (Attachment 1).

[2] *See Case of AO An*, 004/2/07-09-2009-ECCC/OCIJ (PTC 60), Scheduling Order for Pre-Trial Chamber's Hearing on Appeals Against Closing Orders, 3 June 2019, D359/5, p. 2.